## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណ ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ***ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)*** និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខៈ **១០៧៧ សជណ** របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃ ចេញសេចក្តីប្រកាសលេខៈ **២៩០១ ប្រក** ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា សម្រេចចុះឈ្មោះឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមបំណាច់ឆ្នាំ២០២៤ សមាគមមានសមាជិកសរុបចំនួន ៣២២ស្ថានីយ / ក្រុមហ៊ុន ដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកអាជីពចំនួន ២៧៦ ស្ថានីយ និងសមាជិកគាំទ្រចំនួន ៤៦ក្រុមហ៊ុន។

## ២. ការខារស្ដួលសមាគម

### ២.១ សន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជាលើកទី៥

នៅថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានសហការជាមួយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(ឧ.វ.ប.ន.) រៀបចំសន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជាលើកទី៥ ឆ្នាំ២០២៤។ ក្រោមប្រធានបទ «**ទឹកដើម្បីនិរន្តរភាពអនាគត**»។ សន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥ ក្រោមកិច្ចគាំទ្រពីកម្មវិធី CAPRED និងសមាគមទឹកអូស្ត្រាលី (AWA) យើងបានរៀបចំប្រធានបទសំខាន់ៗដែលទាក់ទងទៅនឹងតម្រូវការបច្ចុប្បន្នសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងបានអញ្ជើញ វាគ្មិន នៅក្នុងស្រុក និងក្រៅស្រុក ដែលមានចំណេះដឹង បំណិន និងបទពិសោធន៍ការងារលើវិស័យទឹក ពិសេសការផ្គត់ផ្គង់ទឹកស្អាត មកពិភាក្សា និងធ្វើបទបង្ហាញ ដើម្បីចែករំលែកបទពិសោធន៍ ចំណេះដឹង បំណិន និងបច្ចេកវិទ្យាថ្មីៗជូនដល់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីអ្នកនាងកញ្ញា ភ្ញៀវជាតិ ភ្ញៀវអន្តរជាតិ ប្រតិបត្តិករ និងប្អូនៗនិស្សិតទាំងអស់ដែលបានចូលរួមក្នុងសន្និសីទរបស់យើងនេះ។ ជាងនេះទៅទៀត យើងក៏បានរៀបចំឱ្យមានការដាក់តាំងពិព័រណ៍ផលិតផល និងសេវាកម្ម បច្ចេកវិទ្យាថ្មីៗសម្រាប់វិស័យទឹកស្អាតផងដែរ។

សន្និសីទនិងពិព័រណ៍ទឹកស្អាតកម្ពុជាលើកទី៥នេះ ទទួលបានកិត្តិយសអញ្ជើញចូលរួមជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រី ក្រសួងឧ.វ.ប.ន. **ឯកឧត្តម ដេរិក យីប** ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅកម្ពុជា **លោកស្រី ខូរីន ឆេសមែន** នាយិកាសមាគមទឹកអូស្ត្រាលី **លោក ឡេង ខៀវ** ប្រធានសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងមានអ្នកចូលរួមសរុបចំនួន ៦៦៨នាក់ ស្រី ២០៥នាក់ (ថ្ងៃទី១ សរុប ៣៨៩នាក់ ស្រី១២៣នាក់ និងថ្ងៃទី២ សរុប ២៧៩នាក់ ស្រី៨២នាក់)។

សន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជាលើកទី៥ ទទួលបានការចូលរួមគាំទ្រពីដៃគូសហការចំនួន ៧ស្ថាប័ន រួមមាន៖ ១.កម្មវិធី CAPRED ២.ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន(JICA) ៣.អង្គការ Water.org ៤.សកលវិទ្យាល័យបច្ចេកទេសស៊ីដនី (UTS) ៥. ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (SME BANK) ៦.ក្រុមហ៊ុន iSEA ៧.អង្គការ WaterAid, ព្រមទាំងដៃគូសហការឧបត្ថម្ភចំនួន ១៣ រួមមាន៖ ១)សមាគមទឹកអូស្ត្រាលី (AWA) ២)សមាគមអាជីវកម្មទឹកក្រៅប្រទេសក្រុងគីតាយូស៊ុ (KOWBA) ៣)ក្រុមហ៊ុន លេសសូ(ខេមបូឌា) ត្រេឌីង ឯ.ក ៤)ក្រុមហ៊ុន Molecor Southeast Asia ៥)ក្រុមហ៊ុនវ៉ជើម៉ិច ថេកណូឡូជី ៦)សហគ្រាស អ៊ី-ផៅវ័រ ស៊ីស៊ីអិល ៧)ក្រុមហ៊ុន ខេស៊ីអរអាយ អ៊ិនធើណេសិនណល ខូអបភើរេសិន ឯ.ក ៨)ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA) ៩)ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ១០)ធនាគារកាណាឌីយ៉ា (CANADIA) ១១)គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ ភីអ៊ិលស៊ី (AMK) ១២)ក្រុមហ៊ុន KRL Industries និង ១៣)ក្រុមហ៊ុន អិកវ៉ធើរ ថេកណូឡូជី X-Water។




*រូបភាពទី១៖ ការផ្ដល់កិត្តិយសកាត់ខ្សែបូដោយ ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រី ក្រសួងឧ.វ.ប.ន.*



*រូបភាពទី២៖ រូបភាពអនុស្សាវរីយ៍ក្នុងសន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជាលើកទី៥*

## ២.២ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាសទី៣ នៅការិយាល័យសមាគម និងតាម online ដែលមានអ្នកចូលរួមសរុបចំនួន ១៤នាក់(ស្រី ០៤នាក់)។ កិច្ចប្រជុំមានរបៀបវារៈរួមមាន៖

១. មតិស្វាគមន៍និងបើកកិច្ចប្រជុំ ដោយ លោក ឡេង ខៀវ ប្រធានក្រុមប្រឹក្សាភិបាល
២. លទ្ធផលការងារត្រីមាសទី៣ និងផែនការត្រីមាសទី៤ របស់សមាគម
៣. បុណ្យកឋិនទានរបស់ក្រសួងឧរបន
៤. សន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥
៥. បច្ចុប្បន្នភាពពីសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
៦. ផ្សេងៗ



*រូបភាពទី៣៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាសទី៣*

## ២.៣ សិក្ខាសាលាពិគ្រោះយោបល់ផែនការយុទ្ធសាស្ត្រនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤ សមាគមបានរៀបចំសិក្ខាសាលា«ពិគ្រោះយោបល់ផែនការយុទ្ធសាស្ត្រសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា» នៅសណ្ឋាគារ Cambodiana រាជធានីភ្នំពេញ។ សិក្ខាសាលានេះត្រូវបានសម្របសម្រួលដោយ **លោក ផល វ៉ាន់នី** ទីប្រឹក្សាផ្នែកការអភិវឌ្ឍស្ថាប័ននៃកម្មវិធី CAPRED ។ សិក្ខាសាលានេះមានការចូលរួមពីក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម សមាជិកអាជីព និងសមាជិកគាំទ្រ បុគ្គលិកកម្មវិធី CAPRED សរុបចំនួន ៣១នាក់ (ស្រី ១១នាក់)។ គោលបំណងនៃសិក្ខាសាលា៖

១. ធ្វើបទបង្ហាញ និងពិភាក្សាអំពីចក្ខុវិស័យ បេសកកម្ម ការកំណត់អាទិភាពតួនាទី និងការទទួលខុសត្រូវរបស់សមាគម
២. ឆ្លុះបញ្ចាំងពីការរកឃើញ នៃការធ្វើបច្ចុប្បន្នភាពស្ថានភាពពាក់ព័ន្ធ និងនិន្នាការសំខាន់ៗទាក់ទងនឹងសមាគម និងប្រតិបត្តិករ
៣. ឆ្លុះបញ្ចាំងពីសមាគមលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង (ការវិភាគ SWOT) ដើម្បីបញ្ជាក់ពីការធ្វើរោគវិនិច្ឆ័យរបស់សមាគម

៤. កំណត់សកម្មភាពកែលម្អសំខាន់ៗតាមរយៈការពិភាក្សាជាក្រុម និងការបង្ហាញអំពីភាពខ្លាំង ឱកាស សេចក្តីប្រាថ្នា និងលទ្ធផល (ការវិភាគ SOAR) ដើម្បីកែលម្អសម្រាប់ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។




*រូបភាពទី៤៖ សិក្ខាសាលាពិគ្រោះយោបល់ផែនការយុទ្ធសាស្ត្រសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា*

## ២.៤ ដំណើរទស្សនកិច្ចសិក្សា

### ២.៤.១ ទស្សនកិច្ចសិក្សាក្រៅប្រទេស

**លើកទី១** សមាគមបានដឹកនាំសមាជិកចំនួន ៤០នាក់(ស្រី ១៧នាក់) ទៅចូលរួមក្នុងសន្និសីទ និងពិព័រណ៍ទឹក ២០២៤ (Vietwater & WETV Expo 2024) នៅថ្ងៃទី៥-៧ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាតជាតិ ក្នុងទីក្រុងហូជីមិញ ប្រទេសវៀតណាម។ គោលបំណងដើម្បីសិក្សារៀនសូត្របន្ថែមអំពីវិស័យទឹកស្អាត និងបច្ចេកវិទ្យាថ្មី។ ក្នុងនោះដែរ សមាគម CWA ក៏បានចូលរួមជាវាគ្មិនក្នុងការចែករំលែកពីស្ថានភាពទឹកស្អាតនៅកម្ពុជា និង ឱកាសនៃការវិនិយោគលើវិស័យទឹកស្អាតនៅកម្ពុជាផងដែរ។



*រូបភាពទី៥៖ ការទស្សនការតាំងពិព័រណ៍ និងវេទិកាពិភាក្សានៅប្រទេសវៀតណាម*




*រូបភាពទី៦៖ សមាជិកសមាគមចូលរួមក្នុងសន្និសីទ និងពិព័រណ៍ទឹក ឆ្នាំ២០២៤ នៅប្រទេសវៀតណាម*

**លើកទី២** សមាគម CWA បានទៅចូលរួមនៅក្នុងវេទិកាទឹក (Water Week) នៅថ្ងៃទី៧-៨ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាតជាតិ ទីក្រុងហាណូយ ប្រទេសវៀតណាម។




*រូបភាពទី៧៖ រូបថតជាមួយថ្នាក់ដឹកនាំសមាគមទឹកនៅវៀតណាម និងដៃគូ*

## ២.៤.២ ទស្សនកិច្ចសិក្សាក្នុងប្រទេស

នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាបានសហការជាមួយស្ថានីយផលិតទឹកស្អាតស្វាយរមៀត ក្នុងការរៀបចំទស្សនកិច្ចសិក្សាស្វែងយល់ពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដែលមានទីតាំងស្ថិតនៅភូមិព្រែកតាបែន ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ សមាសភាពអ្នកចូលរួមអញ្ជើញមកពីសមាគមទឹកអូស្ត្រាលី (AWA) សមាជិកជាប្រតិបត្តិករ និងក្រុមហ៊ុន កម្មវិធី CAPRED ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម ព្រមទាំងមានការចូលរួមពីអាជ្ញាធរឃុំផងដែរ។ សកម្មភាពនៅក្នុងទស្សនកិច្ចសិក្សារួមមាន៖

១. បទបង្ហាញអំពីស្ថានីយទឹកស្អាតស្វាយរមៀត (ប្រវត្តិ រចនាសម្ព័ន្ធ ការគ្រប់គ្រងអាជីវកម្ម ការគ្រប់គ្រងផ្នែកផលិត និងយុទ្ធសាស្ត្រធ្វើទីផ្សារ)

២. ការទស្សនាអំពីប្រព័ន្ធសម្អាតទឹករបស់ស្ថានីយ ចាប់ពីប្រភពទឹករហូតដល់អ្នកប្រើប្រាស់ (១. ប្រភពទឹក ២. ប្រពន្ធ័សម្អាតទឹក (ប្រព័ន្ធលាយ និងចាក់បញ្ចូលសារធាតុគីមី, អាងពង្រងកករ, អាងច្រោះ) ៣. អាងស្តុកទឹក ៤. ប្រព័ន្ធបញ្ជូន និងចែកចាយទឹកស្អាត ៥. បន្ទប់ពិសោធន៍ និងការិយាល័យ)។



*រូបភាពទី៨៖ ទស្សនកិច្ចសិក្សានៅស្ថានីយផលិតទឹកស្អាតស្វាយរមៀត ខេត្តកណ្ដាល*



*រូបភាពទី៩៖ សកម្មភាពភ្ញៀវពិនិត្យអាងប្រព្រឹត្តកម្មទឹកស្អាត*

## ២.៥ ការវិភាគគុណភាពទឹកជូនសមាជិក

ក្នុងត្រីមាសទី៤ សមាគមបានផ្តល់ជំនួយបច្ចេកទេស តាមរយៈការផ្តល់ការបង្វឹកទៅលើការអនុវត្តការវិភាគគុណភាពទឹកឆៅ និងធ្វើជ្យាតេស្តជូនដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទំនប់ជើងព្រៃ។



*រូបភាពទី១០៖ សកម្មភាពធ្វើជាតេស្តជូនដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតទំនប់ជើងព្រៃ*

## ២.៦ ការចុះសួរសុខទុក្ខ និងបង្វឹកដល់សមាជិក

នៅក្នុងត្រីមាសទី៤ សមាគម បានចុះទៅស្ថានីយទឹកស្អាតចំនួន ៥ស្ថានីយ ក្នុងគោលបំណងដើម្បីសួរសុខទុក្ខ និងពិភាក្សាអំពីបញ្ហាប្រឈមនានាដែលស្ថានីយបានជួបប្រទះព្រមទាំងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនានាជូនស្ថានីយ ដូចខាងក្រោម៖

១. ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត វ៉ាត ណារុន ខេត្តកំពង់ចាម។
២. ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទឹកធា ខេត្តកំពង់ចាម។
៣. ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំទន្លេបិទ ខេត្តត្បូងឃ្មុំ។
៤. ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ប៉ោ ចាន់ថា ខេត្តកំពង់ធំ។
៥. ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។




*រូបភាពទី១១៖ បុគ្គលិកសមាគមចុះសួរសុខទុក្ខ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសជូនសមាជិក*

## ២.៦ កិច្ចគាំពារសមាជិក

ក្នុងត្រីមាសទី៤នេះ សមាគមបានដឹកនាំសមាជិកដែលជាប្រតិបត្តិករទឹកស្អាតឯកជន ដើម្បីចូលរួមដោះស្រាយបញ្ហាខូចខាតបណ្តាញបំពង់ទឹកស្អាតជូនសមាជិកចំនួនពីរ (២) ស្ថានីយ រួមមាន៖

១. **ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្រពុំឈូក៖** នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ មានសមាជិកចូលរួមចំនួន ២៤ នាក់ ចូលរួមកិច្ចប្រជុំដោះស្រាយទំនាស់នៃការខូចខាតបំពង់ទឹកស្អាតដោយសារការស្ថាបនាផ្លូវ។ កិច្ចប្រជុំនេះក្រោមការសម្របសម្រួលលោកអភិបាលនៃគណអភិបាលស្រុកកោះអណ្តែត និងមានការចូលរួមពីមន្ទីរ ឧ.វ.ប.ន មន្ទីរអភិវឌ្ឍន៍ជនបទ អាជ្ញាធរឃុំ និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ ជាលទ្ធផល ភាគីទាំងសងខាងបានឯកភាពគ្នាទទួលយកដំណោះស្រាយឈ្នះៗ ដោយព្រមព្រៀងគ្នាបង្កើតគណកម្មការចុះវាស់វែងការខូចខាតបំពង់ទឹកស្អាត និងចេញថ្លៃផលប៉ះពាល់បណ្តាញទៅដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្រពុំឈូកចំនួន ៥០ភាគរយ។ ក្នុងនោះដែរ សមាគមបានចាត់បញ្ជូនវិស្វករជាន់ខ្ពស់ទឹកស្អាត ទៅចូលរួមក្នុងគណកម្មការវាស់វែងនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤។





*រូបភាពទី១២៖ កិច្ចប្រជុំដោះស្រាយទំនាស់នៃការខូចខាតបំពង់ទឹកស្អាតដោយសារការស្ថាបនាផ្លូវ*

ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤ វិស្វករជាន់ខ្ពស់ទឹកស្អាត សមាគមបានសហការជាមួយ **លោក លី ស៊ីដា** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្រពុំឈូក មេឃុំ ក្រុមប្រឹក្សាឃុំក្រពុំឈូក និងបុគ្គលិករបស់ក្រុមហ៊ុនស្ថាបនាផ្លូវ ក្នុងការវាស់វែងពីផលប៉ះពាល់នៃបណ្តាញទឹកស្អាត ដែលរងការខូចខាត។





*រូបភាពទី១៣៖ ការវាស់វែងពីផលប៉ះពាល់នៃបណ្តាញទឹកស្អាត ដែលរងការខូចខាត*

**២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ពោធិបាន៖** នៅរសៀលថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ មានសមាជិកចូលរួមចំនួន ២៥នាក់/ស្ថានីយ ចូលរួមដោះស្រាយបញ្ហាខូចខាតបណ្ដាញទុយោទឹកស្អាតដែលបណ្ដាលមកពីក្រុមហ៊ុនធ្វើផ្លូវ ក្នុងឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្ដាល។ កិច្ចប្រជុំនេះមានការចូលរួមសម្របសម្រួលដោយ លោកអភិបាលរងស្រុក និងមេឃុំពោធិបាន។ ជាលទ្ធផល ខាងក្រុមហ៊ុនធ្វើផ្លូវយល់ព្រមសងសំណងដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតពោធិបាន ប្រមាណ ៥៧%នៃថ្លៃខូចខាត និងយល់ព្រមក្នុងការសហការជាមួយស្ថានីយទឹកស្អាត ដើម្បីបញ្ចៀសការខូចខាតបំពង់ទឹកស្អាតជាអតិបរមានាពេលខាងមុខ។ កិច្ចប្រជុំរៀបចំឡើងនៅសាលាឃុំ ពោធិបាន ស្រុកកោះធំ ខេត្តកណ្ដាល និងបញ្ចប់នៅវេលាម៉ោង ១៦:១៥នាទីល្ងាច។



*រូបភាពទី១៤៖ កិច្ចប្រជុំដោះស្រាយទំនាស់នៃការខូចខាតបំពង់ទឹកស្អាតដោយសារការស្ថាបនាផ្លូវ*

## ២.៧ កម្មវិធីផ្សព្វផ្សាយអំពីសេវាកម្មទឹកស្អាតរបស់សមាជិក

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានដឹកនាំសមាជិកចូលរួមក្នុងកម្មវិធីសំណេះសំណាល និងបង្ហាញផែនការពង្រីកបណ្ដាញទឹកស្អាតរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រៃកវាំង ដែលមានទីតាំងនៅភូមិព្រៃកវាំង ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ សមាសភាពអ្នកចូលរួមអញ្ជើញមកពី ១). មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ឆ្នាំង ២).ក្រុមប្រឹក្សាឃុំ និងមេភូមិ ៣). ប៉ុស្តិ៍ប៉ូលីស ៤). មណ្ឌលសុខភាព ៥). សាលារៀន ៦). សហគមន៍ ៧). ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និង៨). សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ កិច្ចប្រជុំមានគោលបំណងដូចខាងក្រោម៖

១. បង្ហាញអំពីវឌ្ឍនភាពនៃអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងផែនការពង្រីកបណ្ដាញថ្មី
២. បង្កើនទំនាក់ទំនង និងកិច្ចសហការល្អជាមួយអាជ្ញាធរគ្រប់លំដាប់ និងអតិថិជន
៣. ថ្លែងអំណរគុណអាជ្ញាធរគ្រប់លំដាប់ និងអតិថិជនដែលបានគាំទ្រដល់ស្ថានីយ
៤. បង្កើនការយល់ដឹងបន្ថែមអំពីសេវាកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រៃកវាំង។



*រូបភាពទី១៥៖ កម្មវិធីសំណេះសំណាល និងបង្ហាញផែនការពង្រីកបណ្តាញទឹកស្អាតរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រែករាំង*

# ៣. កិច្ចសហប្រតិបត្តិការ

## ៣.១ កិច្ចសហការអន្តរជាតិ

### ៣.១.១ ដំណើរទស្សនកិច្ចសិក្សាជូនគណៈប្រតិភូសាធារណរដ្ឋឥណ្ឌា

ក្នុងត្រីមាសទី៤នេះ សមាគមបានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សាជូនគណៈប្រតិភូសាធារណរដ្ឋឥណ្ឌា ចំនួន ៧នាក់ ដើម្បីសិក្សារៀនសូត្រ អំពីការផ្គត់ផ្គង់ទឹកស្អាត នៅប្រទេសកម្ពុជាដែលមានសកម្មភាពដូចខាងក្រោម៖

- ព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ សមាគមបានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សាទៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីសិក្សាស្វែងយល់អំពី ការផ្គត់ផ្គង់ទឹកស្អាត ការផលិត និងបច្ចេកទេសនានា។



*រូបភាពទី១៦៖ ទស្សនកិច្ចសិក្សាទៅកាន់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ*

- រសៀលថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ សមាគមបានដឹកនាំគណៈប្រតិភូសាធារណរដ្ឋឥណ្ឌា ចូលជួបសម្តែងការគួរសម និងសិក្សាស្វែងយល់ពីគោលនយោបាយ ច្បាប់គតិយុត្តទាក់ទងទៅនឹងការផ្តល់អាជ្ញាបណ្ណ និងការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា ពីក្រសួង ឧ.វ.ប.ន. ក្រោមអធិបតីភាព ឯកឧត្តម រដ្ឋលេខាធិការ និងឯកឧត្តម អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាតនៅទីស្តីការក្រសួង។



*រូបភាពទី១៧៖ ការចូលជួបសម្តែងការគួរសម និងសិក្សាស្វែងយល់ពីគោលនយោបាយជាមួយក្រសួង ឧវបន*

❖ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤ សមាគមបានដឹកមកគណៈប្រតិភូសាធារណរដ្ឋឥណ្ឌា ដើម្បីស្វែងយល់អំពីការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតរបស់សហគមន៍ស្មសាន នៅរាជធានីភ្នំពេញ និងទស្សនកិច្ចសិក្សានៅ រដ្ឋាករទឹកស្ទោង-តាំងក្រសាំង (ស្ទោង) ខេត្តកំពង់ធំ។



*រូបភាពទី១៨៖ ការស្វែងយល់អំពីការផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាករទឹក ស្ទោង-តាំងក្រសាំង*




*រូបភាពទី១៩៖ ការស្វែងយល់អំពីការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតរបស់សហគមន៍ស្វាសាន*

❖ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ សមាគមបានរៀបចំដំណើរទស្សនាចរណ៍មួយសម្រាប់គណៈប្រតិភូសាធារណរដ្ឋឥណ្ឌាក្នុងនោះមានប្រាសាទចំនួន ៣ ដែលគណៈប្រតិភូបានអញ្ជើញទស្សនា ប្រាសាទអង្គរវត្ត ប្រាសាទតាព្រហ្ម និងប្រាសាទបាយ័ន។



*រូបភាពទី២០៖ គណៈប្រតិភូបានអញ្ជើញទស្សនានៅប្រាសាទអង្គរវត្ត*

❖ ព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ សមាគមបានដឹកនាំគណៈប្រតិភូសាធារណរដ្ឋឥណ្ឌា ដើម្បីធ្វើទស្សនកិច្ចសិក្សា នៅស្ថានីយចម្រោះទឹកកខ្វក់ ខេត្តសៀមរាប។





*រូបភាពទី២១៖ គណៈប្រតិភូសាធារណរដ្ឋឥណ្ឌាទស្សនកិច្ចសិក្សានៅស្ថានីយបោះទឹកកខ្វក់ ខេត្តសៀមរាប*

- ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ សមាគមបានដឹកនាំគណៈប្រតិភូសាធារណរដ្ឋឥណ្ឌាធ្វើទស្សនកិច្ចសិក្សាអំពីចង្វាក់ផលិតកម្មនៃការផលិតទឹកស្អាតនៅរដ្ឋាករទឹកស្វយ័ត សៀមរាប (ភូមិទឹកវិល)។





*រូបភាពទី២២៖ គណៈប្រតិភូសាធារណរដ្ឋឥណ្ឌាទស្សនកិច្ចសិក្សានៅរដ្ឋាករទឹកស្វយ័តសៀមរាប (ភូមិទឹកវិល)*

### ៣.១.២ សិក្ខាសាលាស្តីពី បច្ចេកទេសប្រព័ន្ធចម្រោះទឹក

ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានសម្របសម្រួលអញ្ជើញសិក្ខាកាមចំនួន ២៣នាក់/ស្ថានីយ ដើម្បីចូលរួមសិក្ខាសាលាស្តីពីបច្ចេកទេសប្រព័ន្ធចម្រោះទឹក ដែលរៀបចំដោយក្រុមហ៊ុន Hitachi Zosen Corporation នៅក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។



*រូបភាពទី២៣៖ ការចូលរួមសិក្ខាសាលា បច្ចេកទេសចម្រោះទឹក ខេត្តពោធិ៍សាត់*

### ៣.១.៣ ការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU)

នៅក្នុងត្រីមាសទី៤ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ចំនួន ២

១. នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយសមាគមទឹកអូស្ត្រាលី (AWA) សម្រាប់រយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ដល់ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៧។




*រូបភាពទី២៤៖ ការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងសមាគម AWA & សមាគម CWA*

២. នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ ចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសមាគមអាជីវកម្មទឹកក្រៅប្រទេសក្រុងគីតាឃ្យុស៊ុ (KOWBA) រយៈពេល ៥ឆ្នាំ ចាប់ពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៩។ ក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ក៏មានការផ្តល់កិត្តិយសអញ្ជើញចូលរួមជាសាក្សីពីថ្នាក់ដឹកនាំក្រសួង ឧ.វ.ប.ន. នៃព្រះរាជាណាចក្រកម្ពុជា និង ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ប្រទេសជប៉ុន។




*រូបភាពទី២៥៖ ការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងសមាគម KOWBA & សមាគម CWA*

### ៣.១.៣ សិក្ខាសាលាស្តីពីទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន ២០២៤ លើកទី១៧

នៅថ្ងៃទី២៤-២៥ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានសហការជាមួយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងសាធារណការ និងដឹកជញ្ជូន សមាគមអាជីវកម្មទឹកក្រៅប្រទេសក្រុងគីតាឃ្យុស៊ុ (KOWBA) ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ប្រទេសជប៉ុន រៀបចំសិក្ខាសាលាស្តីពី«ទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន» លើកទី១៧ ក្រោមអធិបតី **ឯកឧត្តម ស៊ឹម ស៊ីថា** រដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយបង្ហាញការវិវត្តជឿនលឿននៃបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីពាក់ព័ន្ធនៃប្រទេសកម្ពុជា និងជប៉ុនក្នុងវិស័យទឹកស្អាត និងអនាម័យ។ សិក្ខាសាលារយៈពេលពីរថ្ងៃ (ថ្ងៃទី២៤-២៥) រួមជាមួយភាគីជប៉ុន ដោយប្រមូលផ្តុំអ្នកជំនាញ អ្នករៀបចំគោលនយោបាយ និងភាគីពាក់ព័ន្ធប្រមាណ ៣០០នាក់ មកពីប្រទេសទាំងពីរ ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនប្រមាណ ៦២ស្ថានីយ។




*រូបភាពទី២៦៖ សិក្ខាសាលាស្តីពីទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន ២០២៤ លើកទី១៧*

## ៣.២ កិច្ចសហការថ្នាក់ជាតិ

ក្នុងត្រីមាសទី៤នេះ សមាគមបានចូលរួមក្នុងកិច្ចប្រជុំជាមួយក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការជាតិមួយចំនួនដូចខាងក្រោម៖

- ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ សមាគមបានចូលរួមក្នុងសិក្ខាសាលាស្តីពី«**យុវជនដឹកនាំក្នុងវិស័យទឹកស្អាត និងអនាម័យ**» ដែលរៀបចំដោយអង្គការ Center for Sustainable Water (CSW) និងឧបត្ថម្ភដោយកម្មវិធី CAPRED។
- ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ សមាគមបានចូលរួមក្នុង«សន្និបាតមីក្រូហិរញ្ញវត្ថុឆ្នាំ២០២៤» ដែលរៀបចំឡើងដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)។
- ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានចូលរួមក្នុងវេទិកាស្តីពី«**ភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល លើកទី៦**» ដែលរៀបចំដោយក្រសួងមហាផ្ទៃ។
- ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ សមាគមបានចូលរួមក្នុងសិក្ខាសាលាបញ្ជ្រាបការយល់ដឹងស្តីពី«**ស្តង់ដាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គការសង្គមស៊ីវិល**» ដែលរៀបចំដោយនិយ័តករគណនេយ្យ និងសវនកម្ម។



*រូបភាពទី២៧៖ សិក្ខាសាលាស្តីពី«ស្តង់ដាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គការសង្គមស៊ីវិល»*

## ៤. ការអភិវឌ្ឍសមាគម និងការផ្សព្វផ្សាយ

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៤ សមាគមមានការផ្សព្វផ្សាយព័ត៌មានតាមរយៈទំព័រហ្វេសប៊ុក ដែលមានលទ្ធផលដូចខាងក្រោម៖

| ល.រ | ការបរិយាយ | តុលា-ធ្នូ ឆ្នាំ២០២៤ |
|---|---|---|
| ១ | ផ្សព្វផ្សាយបាន | ១១៦ដង |
| ២ | មានអ្នកបានឃើញ ( Reach ) | ៣៩,១៥០នាក់ |
| ៣ | មានការចែកចាយបន្ត និងការចូលរួម | ៥៧៥ដង |
| ៤ | សរុបចំនួនអ្នកចុចចូលចិត្ត ( like page ) | ១២,៣៦៣នាក់ |
| ៥ | សរុបចំនួនអ្នក Follower | ១៤,០៥១នាក់ |

## ៥. ការងារគម្រោង

### ៥.១ គម្រោង«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត» គាំទ្រដោយអង្គការ Water.org

#### ៥.១.១ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើផ្នែកបច្ចេកទេស

*ក. ការបង្វឹកស្តីពី«បច្ចេកទេសផលិតទឹកស្អាត និងការថែទាំប្រព័ន្ធ»*

សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួង ឧ.វ.ប.ន. ក្នុងការផ្តល់វគ្គបង្វឹកតាមស្ថានីយផ្ទាល់ក្នុងគោលបំណងឲ្យអ្នកចូលរួមបានសិក្សាស្វែងយល់ និងអនុវត្តអំពីប្រតិបត្តិការ និងថែទាំប្រព័ន្ធសម្អាតទឹក ការតេស្តគុណភាពទឹក និងការកត់ត្រា ដើម្បីបានជាចំណេះដឹង និងដកស្រង់បទពិសោធន៍ល្អៗពីគ្នាទៅវិញទៅមក។

នៅចុងបញ្ចប់វគ្គបង្វឹក អ្នកចូលរួមអាចមានលទ្ធភាព៖

១. ពិនិត្យ និងអនុវត្តការធ្វើតេស្តទឹកលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃតាមរយៈឧបករណ៍តេស្តគុណភាពទឹក
២. កំណត់បានចំណុចដែលត្រូវកែលម្អដល់ស្ថានីយលើផ្នែកបច្ចេកទេស និងពន្យល់បានអនុសាសន៍ដែលត្រូវអនុវត្ត។

នៅក្នុងត្រីមាសទី៤ បុគ្គលិកសមាគមបានចុះសួរសុខទុក្ខ និងផ្តល់វគ្គបង្វឹកដល់សមាជិកចំនួន ១៥ស្ថានីយ ដូចខាងក្រោម៖

| ល.រ | ឈ្មោះស្ថានីយ | ខេត្ត | កាលបរិច្ឆេទ | ចំនួនអ្នកចូលរួម | |
|---|---|---|---|---|---|
| | | | | សរុប | ស្រី |
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត តាអុង | កំពង់ចាម | ០៧-តុលា-២០២៤ | ៣ | ០ |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្ពានថ្មី | កំពង់ចាម | ០៨-តុលា-២០២៤ | ២ | ០ |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រូចឆ្មារ | ត្បូងឃ្មុំ | ១០-តុលា-២០២៤ | ២ | ១ |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បឹងព្រួល | ត្បូងឃ្មុំ | | ៤ | ១ |
| ៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ហេង អេងហ៊ត | ត្បូងឃ្មុំ | ១១-តុលា-២០២៤ | ១ | ០ |
| ៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទីប្រជុំជនកំពង់ថ្ម | កំពង់ធំ | ១៧-តុលា-២០២៤ | ៣ | ០ |
| ៧ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំតេជោអភិវឌ្ឍន៍ | កំពត | ១៨-តុលា-២០២៤ | ៦ | ០ |
| ៨ | ក្រុមហ៊ុន វ៉ធើរ អ៊ិនវ៉ាយរ៉ុនមិន (ដាប់បែល យូ.អ៊ី) វេនឈ័រ ឯ.ក | បាត់ដំបង | ២៨-តុលា-២០២៤ | ៣ | ០ |
| ៩ | ក្រុមហ៊ុនហ្វ្រីន ហ្សូន | បន្ទាយមានជ័យ | ២៩-តុលា-២០២៤ | ៦ | ៣ |
| ១០ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ភ្នំលៀប | បន្ទាយមានជ័យ | ៣០-តុលា-២០២៤ | ៨ | ២ |
| ១១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រហាល | បន្ទាយមានជ័យ | | ៣ | ០ |
| ១២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទឹកជោរមានជ័យ | បន្ទាយមានជ័យ | | ៣ | ១ |
| ១៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត មេសរជ្រៃ-សូភាស | កំពង់ចាម | ១៦-ធ្នូ-២០២៤ | ៣ | ២ |
| ១៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត លីហេង | កំពង់ចាម | | ២ | ២ |
| ១៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បូរីជលសារ | តាកែវ | | ៥ | ១ |
| **សរុប** | | | | **៥៤** | **១៣** |





*រូបភាពទី២៨៖ សកម្មភាពនៃការបង្វឹកស្តីពី«បច្ចេកទេសផលិតទឹកស្អាត និងការថែទាំប្រព័ន្ធ»*





*រូបភាពទី២៩៖ សកម្មភាពអនុវត្តតេស្តគុណភាពទឹក និងធ្វើជ្យាតេស្ត*

## *ខ. វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេស*

នៅក្នុងត្រីមាសទី៤នេះ សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់ប្រតិបត្តិករឯកជនចំនួន ២លើក

១. នៅថ្ងៃទី២៥-២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ វគ្គបណ្តុះបណ្តាលស្តីពី«**ការគ្រប់គ្រងទឹកគ្មានចំណូល**» នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ បង្រៀនដោយគ្រូជំនាញបច្ចេកទេសអញ្ជើញមកពីប្រទេសឥណ្ឌូនេស៊ី និងមានការចែករំលែកចំណេះដឹង មេរៀន និងឧបករណ៍ពីការគ្រប់គ្រងទឹកគ្មានចំណូល។

សមាសភាពអ្នកចូលរួមសរុបមានចំនួន ៥៤នាក់(ស្រ្តី ១២នាក់) ដែលអញ្ជើញមកពី អគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួង ឧ.វ.ប.ន. តំណាងអង្គការ Water.org កម្ពុជា និងឥណ្ឌូនេស៊ី ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងបុគ្គលិកសមាគម។ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល អ្នកចូលរួមនឹងមានលទ្ធភាព៖

ក. ពន្យល់បានពីលក្ខណៈ មូលហេតុ និងលទ្ធផលនៃការលេចជ្រាប

ខ. កំណត់បានពីបច្ចេកទេសគ្រប់គ្រងទឹកគ្មានចំណូលសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី៣០៖ រូបថតអនុស្សាវរីយ៍ក្នុងវគ្គបណ្តុះបណ្តាល*




*រូបភាពទី៣១៖ សកម្មភាពចូលរួមក្នុងវគ្គបណ្តុះបណ្តាល*

### ៥.១.២ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

វគ្គបណ្តុះបណ្តាលស្តីពី«**គោលការណ៍ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់សហគ្រាសផ្គត់ផ្គង់ទឹកស្អាត**» ចំនួនពីរវគ្គដូចខាងក្រោម៖

**វគ្គទី១៖** ថ្ងៃទី១៤-១៦ ខែតុលា ឆ្នាំ២០២៤ ធ្វើនៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ ដែលមានអ្នកចូលរួមសរុបមានចំនួន ៦៤នាក់ (ស្រី២៧នាក់) មកពីអគ្គនាយដ្ឋានទឹកស្អាត ក្រសួង ឧ.វ.បន អង្គការ Water.org ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បុគ្គលិកក្រុមហ៊ុន BanhJi FinTech Co., Ltd ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សមាគមមីក្រូហិរញ្ញវត្ថុ (CMA) និងសមាគម CWA។

**វគ្គទី២៖** ថ្ងៃទី១៨-២០ ខែធ្នូ ឆ្នាំ២០២៤ នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ ដែលមានសមាសភាពអ្នកចូលរួមសរុបចំនួន ៥៦នាក់(ស្រី ៣១នាក់) មកពីអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧ.វ.ប.ន. អង្គការ Water.org ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បុគ្គលិកក្រុមហ៊ុន BanhJi FinTech Co., Ltd និងសមាគម CWA។ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល អ្នកចូលរួមនឹងមានលទ្ធភាព៖

ក. ស្វែងយល់ពីការសម្រេចចិត្តសំខាន់ៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេ និងកំណត់កម្រិតនៃសិទ្ធិនៃការសម្រេចចិត្តដែលមានសារៈសំខាន់ក្នុងការរៀបចំគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ

ខ. ស្វែងយល់ពីគោលការណ៍ និងនីតិវិធីគណនេយ្យសំខាន់ៗក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់ដោយផ្អែកលើ CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម

គ. រៀបចំគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុដែលត្រូវតាមតម្រូវការរបស់សហគ្រាស។



*រូបភាពទី៣២៖ រូបថតអនុស្សាវរីយ៍ក្នុងវគ្គបណ្តុះបណ្តាល*





*រូបភាពទី៣៣៖ កម្មវិធីបើកវគ្គបណ្តុះបណ្តាល*

### ៥.១.៣ ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

ក្រុមការងារគម្រោងបានសម្របសម្រួល និងតាមដានសមាជិកដែលទទួលបានប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ(FIs)។ ជាលទ្ធផលប្រតិបត្តិករចំនួន១ស្ថានីយបានទទួលប្រាក់កម្ចីដើម្បីពង្រីកអាជីវកម្មចំនួនប្រមាណ **២៨៥.០០០ដុល្លារអាមេរិក** ពីធនាគារ SME Bank។ ទន្ទឹមនឹងនេះ ស្ថានីយចំនួន១ទៀត កំពុងសិក្សាកម្ចីពីធនាគារ SME Bank ផងដែរ។

ក្រៅពីនេះសមាគមក៏បានណែនាំប្រតិបត្តិករដែលមានតម្រូវការកម្ចីឱ្យទំនាក់ទំនងទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុដែលជាដៃគូរបស់សមាគម និងអង្គការ Water.org ផងដែរ។

### ៥.១.៤ កិច្ចប្រជុំក្នុងគម្រោង

នៅក្នុងត្រីមាសទី៤ ក្រុមការងាររបស់គម្រោងបានរៀបចំកិច្ចប្រជុំដូចខាងក្រោម៖

១. ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ ក្រុមការងារសមាគមបានជួបប្រជុំជាមួយម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាលាលេខ ៥ ក្រុមហ៊ុន iSEA និងអង្គការ Water.org ដើម្បីពិភាក្សា និងពិនិត្យលើផែនការវិនិយោគ

សម្រាប់ការរៀបចំផែនការមេ និងផែនការអាជីវកម្ម ៥ឆ្នាំ ក្នុងគម្រោង «ការកែលម្អការគ្រប់ដណ្ដប់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ដើម្បីឱ្យប្រជាជនមានទឹកស្អាតប្រើប្រាស់»

២. ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្រុមការងារគម្រោង (CWA & Water.org) បានជួបប្រជុំដើម្បីពិភាក្សាឆ្លុះបញ្ចាំងអំពីគម្រោង និងសកម្មភាពសម្រាប់គម្រោងថ្មី។

៣. ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៤ ក្រុមការងារគម្រោង (CWA & Water.org) បានជួបប្រជុំដើម្បីពិភាក្សាលើផែនការសកម្មភាព ផែនការថវិកា និងគម្រោងសំណើថ្មី។



*រូបភាពទី៣៤៖ កិច្ចប្រជុំជាមួយស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាលាលេខ ៥ ក្រុមហ៊ុន iSEA និងអង្គការ Water.org*

## ៥.១.៥ សិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង

គម្រោងនឹងត្រូវបញ្ចប់នៅចុងខែធ្នូ ឆ្នាំ២០២៤ សមាគមបានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង ដើម្បីបង្ហាញអំពីលទ្ធផល បញ្ហាប្រឈម និងមេរៀនរៀនសូត្រនៃការអនុវត្តគម្រោងក្នុងរយៈពេលពីឆ្នាំកន្លងមកនៅសៀលថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤។ ជាលទ្ធផលមានអ្នកចូលរួមសរុបចំនួន ៣៥នាក់ មកពីស្ថានីយទឹកស្អាត ២៦ស្ថានីយ អង្គការ Water.org ចំនួន ២នាក់ និងបុគ្គលិកសមាគមចំនួន ៤នាក់។



*រូបភាពទី៣៥៖ ពិភាក្សាក្រុមដើម្បីឆ្លុះបញ្ចាំងអំពីគម្រោង*

## ៥.២. គម្រោង«សហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកបដោយបរិយាប័ន្ន» (EMW)

ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានជួបប្រជុំជាមួយអង្គការ EMW ទីប្រឹក្សារបស់មូលនិធិ DFAT ព្រមទាំងដៃគូរបស់អង្គការ EMW (អង្គការ WOMEN អង្គការ DPO) ដើម្បីពិភាក្សាពីការអនុវត្តគម្រោងកន្លងមក និងប្រមូលសំណូមពរ អនុសាសន៍ពីដៃគូអនុវត្តគម្រោងទាំងអស់។



*រូបភាពទី៣៦៖ កិច្ចប្រជុំជាមួយក្រុមការងារអង្គការ EMW ទីប្រឹក្សារបស់មូលនិធិ DFAT*

## ៥.៣. គម្រោង «ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹក សម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធននឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា»

តាមរយៈការឧបត្ថម្ភពីមហាវិទ្យាល័យបច្ចេកវិទ្យាទីក្រុងស៊ីដនី University of Technology Sydney (UTS) សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) សហការជាមួយរដ្ឋបាលស្រុកសាមគ្គីមានជ័យ បានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោង«**ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹកសម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា**» នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ នៅសាលាស្រុកសាមគ្គីមានជ័យ។ កិច្ចប្រជុំមានគោលបំណង៖

១. ឆ្លុះបញ្ចាំងពីដំណើរការរៀបចំឯកសារផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត។
២. ឆ្លុះបញ្ចាំងអំពីការរៀបចំ និងអនុវត្តលើវិធានការកាត់បន្ថយពីផលប៉ះពាល់គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់សម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាត។
៣. បង្ហាញពីលទ្ធផល បញ្ហាប្រឈម និងមេរៀនរៀនសូត្រដែលទទួលបានពីការអនុវត្តគម្រោង។

សមាសភាពអ្នកចូលរួមក្នុងកិច្ចប្រជុំនេះសរុបមានចំនួន ២២នាក់(ស្រី ១៣នាក់) ដែលអញ្ជើញមកពីរដ្ឋបាលស្រុកសាមគ្គីមានជ័យ ក្រុមប្រឹក្សាឃុំដែលអញ្ជើញមកពីឃុំទាំង៥រួមមាន៖ ឃុំស្វាយ ឃុំស្វាយជុក ឃុំត្បែងខ្ពស់ ឃុំពាម និងឃុំសេដ្ឋី ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនក្នុងស្រុកសាមគ្គីមានជ័យ សហគមន៍ អង្គការ WaterAid អង្គការ CDRI និងសមាគម CWA។





*រូបភាពទី៣៧៖ កិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោងដែលគាំទ្រដោយ UTS*

## ៥.៤. គម្រោង «ការជ្រើសរើសប្រតិបត្តិករឯកជនឆ្នើមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត» (JICA)

សមាគមបានសហការជាមួយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តជាតិជប៉ុន (JICA) ក្នុងការអនុវត្តគម្រោងមួយដែលមានឈ្មោះថា «**ការជ្រើសរើសប្រតិបត្តិករឯកជនឆ្នើមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត**»។ គោលបំណងចម្បងរបស់គម្រោងនេះគឺ «**ការរៀនជាមួយគ្នា**» ហើយមានគោលដៅដើម្បីកែលម្អប្រតិបត្តិករដោយចែករំលែកចំណេះដឹង បំណិន និងបទពិសោធន៍របស់ពួកគេ។ គម្រោងនេះស្វែងរកការអនុវត្តន៍ល្អៗរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងចែករំលែកយ៉ាងទូលំទូលាយជាមួយនឹងប្រតិបត្តិករដទៃទៀត។

ក្នុងត្រីមាសទី៤ នេះ ក្រុមការងារចុះសិក្សាលម្អិតដល់ស្ថានីយសម្រាប់ប្រតិបត្តិករដែលបានជ្រើសរើសទាំង ១០ ស្ថានីយ និងបានសម្រេចជ្រើសរើសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឆ្នើមចំនួន ៥ស្ថានីយ។





*រូបភាពទី៣៨៖ ក្រុមការងារចុះសិក្សាលម្អិតដល់ស្ថានីយ និងប្រភពទឹក*





*រូបភាពទី៣៩៖ ក្រុមការងារចុះសិក្សាពីប្រព័ន្ធម៉ូទ័រចែកចាយទឹក និងស្តុក*

បន្ទាប់ពីការជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យយ៉ាងល្អិតល្អន់ ប្រតិបត្តិករមួយចំនួនខាងក្រោមត្រូវបានជ្រើសសម្រាប់ពានរង្វាន់៖

### ក. ជ័យលាភីពានរង្វាន់នៃការអនុវត្តន៍ល្អបំផុត

| | |
|---|---|
| <u>ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទតូច</u> | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់កុង |
| <u>ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទមធ្យម</u> | ចំណាត់ថ្នាក់លេខ ១៖ ក្រុមហ៊ុន ឆ្លូង ឌីស្ទ្រីក វ៉ាធើរ ស៊ីបផ្លាយ ឯ.ក<br>ចំណាត់ថ្នាក់លេខ ២៖ ក្រុមហ៊ុន សសស្តេម្ភ វ៉ាធើរ ស៊ីបផ្លាយ ឯ.ក |
| <u>ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទធំ</u> | ចំណាត់ថ្នាក់លេខ ១៖ ក្រុមហ៊ុន ខោលបុលទឹកស្អាត ឯ.ក<br>ចំណាត់ថ្នាក់លេខ ២៖ ក្រុមហ៊ុន ពួកឌីស្ទ្រីក វ៉ាធើរ ស៊ីបផ្លាយ ខូ អិលធីឌី |







*រូបភាពទី៤០៖ **ឯកឧត្តម អ៊ុំ សុថា រដ្ឋលេខាធិការ** ប្រគល់ពានរង្វាន់នៃការអនុវត្តន៍ល្អបំផុតជូនប្រតិបត្តិករ*

## ខ. ពានរង្វាន់ គំរូនៃការអនុវត្តន៍ល្អ

| | |
|---|---|
| ចំណាត់ថ្នាក់ ប្រតិបត្តិករ តូច | ១ .ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់កុង |
| ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទមធ្យម | ១ .ក្រុមហ៊ុន ឆ្លង ឌីស្រ្ទីក វ៉ាធើរ សឹបផ្លាយ ឯ.ក<br>២ .ក្រុមហ៊ុន សសស្តម្ភ វ៉ាធើរ សឹបផ្លាយ ឯ.ក<br>៣ .ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្បែងខ្ពស់ |
| ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទធំ | ១ .ក្រុមហ៊ុន ខោលបុលទឹកស្អាត ឯ.ក<br>២ .ក្រុមហ៊ុន ពួកឌីស្រ្ទីក វ៉ាធើរ សឹបផ្លាយ ខូ អិលធីឌី<br>៣ .ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សូទ្រនិគម |
| *ពានរង្វាន់ពិសេស* | ១. ក្រុមហ៊ុន ខ្មែរ វ៉ាធើរ សិបផ្លាយ ហូលឌីង ខូ អិលធីឌី (KWSH) |

















*រូបភាពទី៤១៖ **ឯកឧត្តម ស៊ឹម ស៊ីថា** និង**ឯកឧត្តម សយ ភីរម្យ** រដ្ឋលេខាធិការ ប្រគល់ពានរង្វាន់គំរូនៃការអនុវត្តន៍ល្អជូនប្រតិបត្តិករ*

បន្ថែមពីនេះទៀត ក្រុមការងារបានចងក្រងសៀវភៅមួយដែលបានប្រមូលផ្តុំបញ្ហាមួយចំនួនដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បាននឹងកំពុងជួបប្រទះ ក៏ដូចជា «**ការអនុវត្តល្អៗ**» ដែលបានជួយដោះស្រាយបញ្ហាទាំងអស់នោះ។ ករណីសិក្សា ឬឧទាហរណ៍ទាំងអស់នេះអាចប្រើជាឯកសារយោងសម្រាប់ប្រតិបត្តិករដទៃទៀត យកមកអនុវត្តដើម្បីកែលម្អប្រតិបត្តិការរបស់ពួកគេ។ សៀវភៅនេះបានចែករំលែកក្នុងកម្មវិធីសន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជាលើកទី៥។

ខាងក្រោមនេះគឺជាតំណភ្ជាប់ក្នុងការទាញយកឯកសារ!

https://www.cwa.org.kh/wp-content/uploads/2025/01/Booklet-of-Essay_Kh.pdf




*រូបភាពទី៤២៖ សៀវភៅគំរូនៃការអនុវត្តន៍ល្អ*